**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើត

## គណៈកម្មការកម្ពុជា សំរាប់ស្រាវជ្រាវរួមគ្នាជាមួយភាគីថៃ អំពីវិស័យវប្បធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ :** គណៈកម្មការកម្ពុជា សំរាប់ស្រាវជ្រាវរួមគ្នាជាមួយភាគីថៃ អំពីវិស័យវប្បធម៌ ដើម្បីបើក

វេទិកាសំរាប់ការត្រិះរិះពិចារណារួមគ្នា លើការអប់រំមុខវិជ្ជាប្រវត្តិសាស្ត្រ និងវប្បធម៌ ជាពិសេស លើសៀវភៅសិក្សានៅសាលារៀន ក្នុងគោលបំណងស្ថាបនានូវមនសិការប្រវត្តិ-សាស្ត្រស្របគ្នាមួយ ឈានទៅកាត់បន្ថយអរិភាព និងបង្កើនការយោគយល់គ្នា តាមរយៈការយល់ដឹងត្រឹមត្រូវទៅវិញទៅមក សំរាប់ការពង្រឹង និងអភិវឌ្ឍន៍ទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការយូរអង្វែង រវាងប្រទេសទាំងពីរ ។

**មាត្រា ២ :** គណៈកម្មការខាងភាគីកម្ពុជា មានសមាសភាព ដូចតទៅ :

| | |
|---|---|
| ១-ឯកឧត្តម ស៊ន សំណាង | ប្រធាន |
| ២-ឯកឧត្តម ពិត ចំណាន | អនុប្រធាន |
| ៣-ឯកឧត្តម ស្វាយ ស៊ីថា | អនុប្រធាន |
| ៤-បណ្ឌិត អ៊ីវ ច័ន | អគ្គលេខាធិការ |
| ៥-ឯកឧត្តម នុត ណារ៉ាង | សមាជិក |
| ៦-ឯកឧត្តម ឡុង សៀម | សមាជិក |
| ៧-ឯកឧត្តម ឆយ យីហ៊ាង | សមាជិក |
| ៨-ឯកឧត្តម រស់ ចន្ទ្រាបុត្រ | សមាជិក |
| ៩-ឯកឧត្តម មីសែល ត្រាណេ | សមាជិក |
| ១០-បណ្ឌិត ព្រុំ ម៉ល់ | សមាជិក |
| ១១-ឯកឧត្តម ពៅ សាមី | សមាជិក |
| ១២-ឯកឧត្តម ស៊ុំ ឈុំប៊ុន | សមាជិក |
| ១៣-លោក យី ធន់ | សមាជិក |
| ១៤-បណ្ឌិត ខៀវ ថារិកា | សមាជិក |
| ១៥-បណ្ឌិត អ៊ុង ជិនណារី | សមាជិក |
| ១៦-លោក ស៊ន សូផាត | សមាជិក |
| ១៧-បណ្ឌិត ឃីង ហុកឌី | សមាជិក |
| ១៨-បណ្ឌិត ផែល ថោង | សមាជិក |

១៩-បណ្ឌិត ឃឹន សុខ សមាជិក
២០-បណ្ឌិត ម៉ក់ ភឺន សមាជិក
២១-ឯកឧត្តម លី គឹមសុខ សមាជិក

មាត្រា ៣ : គណៈកម្មការនេះ ធ្វើការប្រជុំក្រុមឯកទេស ៣ខែម្តង និង ការប្រជុំរួម ៦ខែម្តង។ ប្រធានគណៈកម្មការមានភារកិច្ចកោះប្រជុំ ក្នុងករណីចាំបាច់ តាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ទីកន្លែង និងកាលបរិច្ឆេទនៃការប្រជុំ នឹងត្រូវកំណត់តាមការឯកភាព ពីភាគីទាំងសងខាង។ អនុសាសន៍នៃការប្រជុំរួមនីមួយៗនឹងត្រូវដាក់ជូនរដ្ឋាភិបាល នៃប្រទេសទាំងពីរសំរាប់ការពិចារណា និងចាត់វិធានការអនុវត្ត តាមលទ្ធភាពជាក់ស្តែង។

មាត្រា ៤ : គណៈកម្មការខាងភាគីកម្ពុជា ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ៥ : ថវិកាសំរាប់ធានាដំណើរការក្នុងលេខាធិការដ្ឋាន និងក្នុងការប្រជុំនានា ដែលរៀបចំនៅក្នុងប្រទេសកម្ពុជា ជាថវិកាជាតិ តាមគំរោងដែលស្នើឡើងដោយគណៈកម្មការ ខាងភាគីកម្ពុជា តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា ៦ : គណៈកម្មការនេះមានសិទ្ធិពិនិត្យ ផ្តល់ការយល់ព្រម និងទទួលជំនួយគ្រប់ផ្នែក ពីប្រភពផ្សេងៗទៀត។

មាត្រា ៧ : គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការឯកទេសផ្សេងៗទៀត តាមការឯកភាព ពីភាគីទាំងសងខាង។

មាត្រា ៨ : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៩ :** គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់រាជបណ្ឌិតសភាកម្ពុជា ។

**មាត្រា ១០ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងសមាជិកគណៈកម្មការដែលមាននាមចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- ឯកសារ-កាលប្បវត្តិ